## លិខិតចំហរជូនចំពោះ
## រដ្ឋាភិបាលនិងអ្នកធ្វើគោលនយោបាយនៅក្នុងអាស៊ី

## ប្រធានបទ: ការដាស់តឿន អំពីគ្រោះថ្នាក់សុខភាព ស្តីពី សារធាតុអាសបេស្តុស គ្រីសូថាយល៍ ( Chrysotile Asbestos )

ក្នុងនាមយើង ជាអ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រ វេជ្ជបណ្ឌិត អ្នកឯកទេសផ្នែកសុខភាពវិជ្ជាជីវៈ ការងារនិងជំងឺដែលទាក់ទងទៅនឹងសារធាតុអាសបេស្តុស (Asbestos-Related Disease (ARDs)) មកពីជុំវិញពិភពលោក រួមជាមួយ តំណាងក្រុមជនរងគ្រោះដោយសារសារធាតុ អាសបេស្តុស និងសហជីពដែលបានគាំទ្រលិខិតចំហនេះ ផ្ញើជូនដល់រដ្ឋាភិបាលនិងអ្នកធ្វើគោលនយោបាយ ដើម្បីបង្ហាញពីភាពស្មោះត្រង់ និងការព្រួយបារម្ភយ៉ាងជ្រាលជ្រៅរបស់យើង អំពីការបន្តប្រើប្រាស់សារធាតុ អាសបេស្តុស គ្រីសូថាយល៍ នៅក្នុងប្រទេសជាច្រើននៅក្នុងតំបន់អាស៊ី។ បើទោះបីជាមានភស្តុតាងច្បាស់លាស់ និងភាពជាក់លាក់នៃជំងឺមហារីក ព្រមទាំងហានិភ័យនៃជំងឺផ្សេងទៀត ដែលទាក់ទងជាមួយនឹងការបន្តប្រើប្រាស់សារធាតុ អាសបេស្តុស។

យើងសូមស្នើអ្នកទាំងអស់គ្នា ផ្តោតការចិត្តទុកដាក់ដូចខាងក្រោម នៅពេលអ្នកធ្វើការពិចារណា អំពីការបន្តប្រើប្រាស់ផលិតផលនេះ នាពេលអនាគតនៅក្នុងប្រទេសរបស់ខ្លួន។

- ✓ សារធាតុអាសបេស្តុស គ្រីសូថាយល៍ គឺជាបុព្វហេតុចំបង បង្កឲ្យមានជម្ងឺដែលទាក់ទងទៅនឹងសារធាតុអាសបេស្តុស (ARD) នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ។ ដោយគ្មានការសង្ស័យទេថា សារធាតុអាសបេស្តុស គ្រីសូថាយល៍ រួមទាំងសារធាតុអាសបេស្តុសប្រភេទផ្សេងទៀត ជាអ្នកបង្កឱ្យមានជំងឺមហារីកសួត, មេសូតេលីយូម៉ា (mesothelioma), អាបេស្តូស៊ីស (asbestosis) មហារីកបំពង់ក និងមហារីកអូវែ (ovarian cancer) ។ មានភ័ស្តុតាងអន្តរជាតិជាច្រើន ស្តីពីប្រភេទជំងឺមហារីក ដែលមានទាក់ទងផ្ទាល់ជាមួយ គ្រីសូថាយល៍ (chrysotile) ត្រូវបានចងក្រងជាឯកសារយ៉ាងច្បាស់លាស់ដោយទីភ្នាក់ងារអន្តរជាតិដើម្បីស្រាវជ្រាវជំងឺមហារីក (IARC)[1]។
- ✓ ការតវ៉ា ពីក្រុមអ្នកតស៊ូមតិ ឲ្យបន្តការប្រើប្រាស់ សារធាតុអាសបេស្តុស គ្រីសូថាយល៍ បានលើកឡើងថា សរសៃឆ្មារ គ្រីសូថាយល៍ នឹងរំលាយបាត់នៅក្នុងសួតក្នុងរយៈពេល 14 ថ្ងៃ គឺជាព័ត៌មានក្លែងក្លាយ(កុហក់)ទាំងស្រុង[2]។

- ✓ ការតវ៉ា ពីក្រុមអ្នកតស៊ូមតិ ការបន្តប្រើប្រាស់ សារធាតុអាសបេស្តុស គ្រីសូថាយល៍ បានលើកឡើងថា 80% នៃពិភពលោកនៅតែប្រើប្រាស់ សារធាតុអាសបេស្តុស គ្រីសូថាយល៍ គឺព័ត៌មានក្លែងក្លាយ។ ភាគច្រើននៃបណ្តាប្រទេសនៅលើពិភពលោក បានហាមឃាត់ សារធាតុ គ្រីសូថាយល៍ ជាផ្លូវការ ឬឈប់ប្រើប្រាស់វាដោយសារកើនរតកនៃការស្លាប់ដោយសារជំងឺមហារីករបស់កម្មករនិងសហគមន៍។ មានតែប្រទេសចំនួន 87 ប៉ុណ្ណោះ រាយការណ៍ថានៅក្នុងឆ្នាំ 2015 បានប្រើប្រាស់វត្ថុធាតុដើម សារធាតុអាសបេស្តុសនៅ ហើយភាគច្រើនប្រើបរិមាណតិចតួចបំផុត។ មានតិចជាង 15% នៃប្រទេសចំនួន195របស់អង្គការសហប្រជាជាតិ បានប្រើប្រាស់ សារធាតុអាសបេស្តុស ជាង 1,000 តោនក្នុងឆ្នាំ 2015។ នៅក្នុងឆ្នាំនោះ មានប្រាំពីរប្រទេស

---
[1] http://monographs.iarc.fr/ENG/Classification/
[2] Video clip *www.chrysotile-asia.com/*

នៅលើពិភពលោកបានប្រើច្រើនជាង 50,000 តោន (ពោលមានប្រទេសចិន ឥណ្ឌា ឥណ្ឌូនេស៊ី វៀតណាម អ៊ូសបេគីស្ថាន, រុស្ស៊ី និងប្រេស៊ីល)។ បច្ចុប្បន្ននេះ អាស៊ី ជាតំបន់សំខាន់ចុងក្រោយ ដែលបានប្រើ សារធាតុអាសបេស្តុស គ្រីសូថាយល៍ រហូតមានជាង 75% នៃការប្រើប្រាស់ប្រចាំឆ្នាំរបស់ពិភពលោក[3]។

- ✓ សន្និសីទការងាររបស់អង្គការពលកម្មអន្តរជាតិ នៃរដ្ឋជាសមាជិកទាំងអស់នៅឆ្នាំ 2006 បានប្រកាសថា ការលុបបំបាត់ការប្រើប្រាស់សារធាតុអាសបេស្តុសនៅថ្ងៃអនាគត គឺជាមធ្យោបាយដែលមានប្រសិទ្ធភាពបំផុត ដើម្បីការពារកម្មករដែលរងផលប៉ះពាល់ពីសារធាតុអាសបេស្តុស និងដើម្បីទប់ស្កាត់ជម្ងឺដែលទាក់ទងទៅនិងសារធាតុអាសបេស្តុស (ARD) នាពេលអនាគត[4]។

- ✓ អង្គការសុខភាពពិភពលោក បានលើកម្តងហើយម្តងទៀតថា "វិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការលុបបំបាត់ជំងឺទាក់ទងទៅនឹង សារធាតុអាសបេស្តុស គឺបញ្ឈប់ការប្រើប្រាស់ សារធាតុអាសបេស្តុស គ្រប់ប្រភេទ" [5]។

- ✓ គ្មានទេ "ការប្រើប្រកបដោយសុវត្ថិភាព" នៃការប្រើសារធាតុអាសបេស្តុស ដែលអាចធានាបានតាមរយៈសង្វាក់ផ្គត់ផ្គង់។ ភ័ស្តុតាងបានបង្ហាញបន្តរថា បន្ទុកថ្នាក់ជាតិនៃជម្ងឺដែលទាក់ទងទៅនិងសារធាតុអាសបេស្តុស (ARDs) មានពាក់ព័ន្ធផ្ទាល់ទៅនិងសមាមាត្រនៃការប្រើប្រាស់សារធាតុអាសបេស្តុស។ វាជាភ័ស្តុតាងគាំទ្រលើរបកគំហើញដែលថា បន្ទុកធ្ងន់នៃអត្រាជំងឺដែលទាក់ទងនិងសារធាតុអាសបេស្តុស នៅក្នុងបណ្តាប្រទេសឧស្សាហកម្មនានា គឺដោយសារតែការប្រើប្រាស់សារធាតុអាសបេស្តុសអស់ជាច្រើនទសវត្សរ៍កន្លងមក ។ ទោះបីជាមានការប៉ុនប៉ងក្នុងការធានាថា មានវិធីការប្រើប្រាស់សារធាតុអាសបេស្តុស ប្រកបដោយសុវត្ថិភាពក៏ដោយ[6]។

- ✓ វិទ្យាស្ថានស្រាវជ្រាវអត្រាមរណៈដោយសារជំងឺ បានវាយតម្លៃថា អត្រាស្លាប់ជាសាកលដោយសារ សារធាតុអាសបេស្តុស មានចំនួនជាង 222,000 នាក់ជារៀងរាល់ឆ្នាំ[7] នៅលើពិភពលោក។ តាមការការប៉ាន់ប្រមាណចុងក្រោយរបស់ខ្លួន សម្រាប់ឆ្នាំ 2016 ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ 2017 ។ ភស្តុតាងដែលមានបានបង្ហាញថាសូម្បីតែចំនួនដ៏ច្រើន និងគួរឱ្យព្រួយបារម្ភនេះ ជាចំនួនតិចជាងតួលេខជាក់ស្តែង។

- ✓ "តម្លៃថោក" នៃផលិតផលដែលមានផ្ទុកសារធាតុអាសបេស្តុស ត្រូវបានលើកឡើងជាអំណះអំណាងសម្រាប់ការបន្តប្រើប្រាស់ សារធាតុអាសបេស្តុស ជាពិសេសការផ្គត់ផ្គង់ គ្រឿងសម្ភារៈសំណង់លំនៅដ្ឋានក្នុងតម្លៃថោកសម្រាប់ជនក្រីក្រ។ "តម្លៃថោក" ត្រូវបានគេចាត់ទុកថាជាការប្រៀបធៀបប្រកបដោយយុត្តិធម៌ គឺមិនបានពិចារណាលើសំណងនិងការចំណាយលើការថែទាំសុខភាពនាពេលអនាគត ចំពោះជនរងគ្រោះដោយសារជំងឺដែលទាក់ទង សារធាតុអាសបេស្តុស និងហានិភ័យប៉ះពាល់ដល់អ្នកដែលរស់នៅក្នុងផ្ទះ

[3] USGS - Estimates Of Global Asbestos Production, Trade, & Consumption In 2015
[4] ILO Resolution on Asbestos 2006
[5] Chrysotile Asbestos 2014 WHO http://www.who.int/ipcs/assessment/public_health/chemicals_phc
[6] https://www.ncbi.nlm.nih.gov/pubmed/17350453
[7] 193,374: http://vizhub.healthdata.org/gbd-compare/

ដែលមានដំបូលផ្ទះប្រកបដោយគ្រោះថ្នាក់ ក៏ដូចជាថ្លៃចំណាយលើការរុះរើ និងការបោះចោលប្រកបដោយសុវត្ថិភាពនាពេលអនាគតនៃសម្ភារៈដែលមានផ្ទុកសារធាតុអាសបេស្តុស(ACM) ដែលមាននៅក្នុងសំណង់ និងផលិតផលផ្សេងទៀត។

- ✓ មានសារធាតុជាច្រើនដែលមានសុវត្ថិភាព និងស្ថេរភាពសេដ្ឋកិច្ច ជំនួសឲ្យសម្ភារៈមានផ្ទុកសារធាតុអាសបេស្តុស ដែលមានប្រើប្រាស់រួចហើយនៅក្នុងតំបន់អាស៊ី និងបណ្តាប្រទេសដែលបានហាមឃាត់សារធាតុអាសបេស្តុស[8]។

- ✓ បច្ចេកវិទ្យាគ្មានសារធាតុអាសបេស្តុស ត្រូវបានអភិវឌ្ឍឡើងនៅក្នុងតំបន់ អាស៊ី ដែលវាជាឱកាសមួយដើម្បីបង្កើតការងារក្នុងតំបន់ និងឧស្សាហកម្មបៃតងថ្មីនៅក្នុងតំបន់។

- ✓ មានប្រទេសឧស្សាហកម្មមួយចំនួន ជួបប្រទះនូវភាពចលាចលនិងវិវាទសាធារណៈ ប្រឆាំងជាមួយរដ្ឋាភិបាល ដោយពួកគេយល់ឃើញថា រដ្ឋាភិបាល (បរាជ័យ) ខកខានក្នុងការការពារសុខភាពសាធារណៈ ដោយមិនបានចាត់វិធានការទាន់ពេលវេលានិងសមស្របចំពោះគ្រោះថ្នាក់នៃសារធាតុអាសបេស្តុស។

- ✓ ការសិក្សាស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោកនាពេលថ្មីៗនេះ[9] ទៅលើរាល់ប្រទេសដែលហាមឃាត់សារធាតុអាសបេស្តុស បានបង្ហាញថា គ្មានផលប៉ះពាល់អវិជ្ជមានទៅលើផលិតផលសរុបក្នុងស្រុក (GDP) នៃប្រទេសណាមួយដែលបានហាមឃាត់សារធាតុអាសបេស្តុសទេ។

ដើម្បីសង្គ្រោះជីវិត និងកាត់បន្ថយបន្ទុកនាពេលអនាគត នៃអត្រាជម្ងឺដែលបង្ករដោយសារធាតុអាសបេស្តុស (ARD) ព្រមទាំងជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងជៀសវាងអស្ថិរភាពសង្គម ដែលមិនចាំបាច់នៅក្នុងតំបន់អាស៊ី យើងសូមជំរុញឱ្យរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ ក្នុងការបញ្ឈប់ការប្រើប្រាស់ សំភារៈសំណង់ដែលមានផ្ទុក សារធាតុអាសបេស្តុស និងហាមឃាត់ផលិតផលគ្រប់ប្រភេទដែលមានផ្ទុកសារធាតុ គ្រីសូថាយល៍ សារធាតុអាសបេស្តុស។

[8] Asbestos Economic Assessment of Bans and Declining Production and Consumption; Lucy P. Allen, Jorge Baez, Mary Elizabeth C. Stern and Frank George 201)

[9] Ibid